អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី០៩ ខែឧសភា ឆ្នាំ ២០១១

# សេចក្តីប្រកាសព័ត៌មាន

## សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង០០៣

សហព្រះរាជអាជ្ញាអន្តរជាតិ **Andrew Cayley** សូមធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ អនុលោមតាមវិធាន៥៤នៃវិធានផ្ទៃក្នុង ដើម្បីធានាថាសាធារជនទទួលជ្រាបបានត្រឹមត្រូវអំពីដំណើរការនីតិវិធី អ.វ.ត.ក ដែលកំពុងអនុវត្តជាពិសេសពាក់ព័ន្ធនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងសំណុំរឿង០០៣។ ក្នុងការផ្តល់ជូននូវព័ត៌មាននេះ ផលប្រយោជន៍របស់ជនរងគ្រោះនិងសាក្សី សិទ្ធិរបស់ជនសង្ស័យ និង លក្ខខណ្ឌតម្រូវក្នុងការស៊ើបអង្កេត ត្រូវបានយកមកពិចារណា ដូចបានកំណត់ដោយវិធានផ្ទៃក្នុង។

ក្រោយពីមានការណែនាំរបស់អង្គបុរេជំនុំជម្រះ នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ជូនសហចៅក្រមស៊ើបអង្កេតនូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរចំនួនពីរ ដែលបើកការស៊ើប អង្កេតទៅលើឧក្រិដ្ឋកម្មនានាក្នុងសំណុំរឿង០០៣ និង សំណុំរឿង០០៤។ ដីកាសន្និដ្ឋានទាំងនេះបានរៀបរាប់ ឈ្មោះជនសង្ស័យចំនួនប្រាំ (៥) នាក់ដែលសហព្រះរាជអាជ្ញាជឿជាក់ថាទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់និងស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក។ យោងតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក សហចៅក្រម ស៊ើបអង្កេតតម្រូវឲ្យធ្វើការស៊ើបអង្កេតការចោទប្រកាន់ព្រហ្មទណ្ឌដែលមាននៅក្នុងដីកាទាំងនេះ។

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក្នុងសំណុំរឿង០០៣ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទារុណកម្ម ការដាក់ក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់ ការធ្វើឲ្យទៅជាទាសករ ការធ្វើទុកបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀត។ ប្រសិនបើមានភស្តុតាងបញ្ជាក់ អំពើទាំងនេះអាចបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភទៅលើក្រមព្រហ្មទណ្ឌ កម្ពុជាឆ្នាំ១៩៥៦។

ឧក្រិដ្ឋកម្មដែលតម្រូវឲ្យធ្វើការស៊ើបសួរតាមផ្លូវតុលាការជាផ្នែកមួយនៃសំណុំរឿង០០៣ បានកើតឡើងនៅទីតាំងឧក្រិដ្ឋកម្មនានា និងដំណើររឿងព្រហ្មទណ្ឌក្នុងសំណុំរឿង០០២ ក្នុងនោះរួមមាន៖ មន្ទីរសន្តិសុខស-២១ ទីតាំងសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ការបោសសម្អាតនៅភូមិភាគបូព៌ា ភូមិភាគកណ្តាល និងភូមិភាគឧត្តរថ្មី និងការវាយចូលក្នុងប្រទេសវៀតណាម ក៏ដូចជាទីតាំងឧក្រិដ្ឋកម្មថ្មី និងដំណើររឿងព្រហ្មទណ្ឌនានាដូចខាងក្រោម៖

(១) មន្ទីរសន្តិសុខស-២២ក្នុងតំបន់ភ្នំពេញ

(២) មន្ទីរសន្តិសុខវត្តឥន្ទញាណក្នុងខេត្តកំពង់សោម

(៣) ទីតាំងវាយថ្មស្ទឹងហាវក្នុងខេត្តកំពង់សោម

(៤) ការចាប់ជនបរទេសតាមឆ្នេរសមុទ្រកម្ពុជានិងការដាក់ពួកគេក្នុងមន្ទីរឃុំឃាំងខុសច្បាប់ ការផ្ទេរទៅស-២១ ឬការធ្វើមនុស្សឃាត និង

(៥) មន្ទីរសន្តិសុខនានាដែលដំណើរការនៅក្នុងខេត្តរតនគិរី

នៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ការិយាល័យសហព្រះរាជអាជ្ញាបានទទួលការជូនដំណឹងថា សហចៅក្រមស៊ើបអង្កេតបានពិចារណាឃើញថាការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ ត្រូវបានបញ្ចប់។ ក្រោយពីបានពិនិត្យសំណុំរឿងដោយប្រុងប្រយ័ត្នរួចមក សហព្រះរាជអាជ្ញាអន្តរជាតិមានបំណងស្នើសុំឲ្យមានការបំពេញកិច្ចស៊ើបសួរបន្ថែមទៀតពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ក្នុងរយៈពេល១៥ថ្ងៃ ដូចមានចែងនៅក្នុងវិធាន ៦៦(១)នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។ ក្នុងចំណោមបញ្ហាដទៃទៀត សហព្រះរាជអាជ្ញាអន្តរជាតិនឹងស្នើឲ្យសហចៅក្រមស៊ើបអង្កេត៖

១. កោះហៅ និងសួរចម្លើយជនសង្ស័យក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ក្នុងសំណុំរឿង ០០៣ និងជូនដំណឹងថាពួកគេស្ថិតក្រោមការស៊ើបអង្កេត។

២. ស្តាប់ចម្លើយបុគ្គលបន្ថែមទៀតដែលត្រូវបានកំណត់ថាជាសាក្សីសក្តានុពល។

៣. ស្តាប់ចម្លើយ ឬស្តាប់ចម្លើយឡើងវិញចំពោះសាក្សីដែលកំណត់នៅក្នុងសំណុំរឿង០០២ ដោយផ្តោតលើការចោទប្រកាន់ជាក់លាក់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក្នុងសំណុំរឿង០០៣។

៤. ពិនិត្យបន្ថែមលើទីតាំងឧក្រិដ្ឋកម្ម (ក្នុងនោះរួមមានការស្វែងរកទីតាំងកប់សាកសពរួម)។

៥. ដាក់ភស្តុតាងបន្ថែមទៅក្នុងសំណុំរឿង ក្នុងនោះរួមមានការផ្ទេរបន្ថែមនូវភស្តុតាងពីសំណុំរឿង០០២ ទៅសំណុំរឿង០០៣ និង

៦. ធ្វើការស៊ើបអង្កេតបន្ថែមចំពោះការជាប់ពាក់ព័ន្ធនៅក្នុងឧក្រិដ្ឋកម្មរបស់ជនសង្ស័យក្នុងសំណុំរឿង០០៣ ក្នុងនោះរួមទាំងការផ្ទេរអ្នកទោសក្រោមការគ្រប់គ្រងរបស់ស-២១ ការទទួល "ចម្លើយសារភាព"ដែលស្រង់ពីអ្នកទោសដែលត្រូវបានសម្លាប់នៅស-២១ និងការជាប់ពាក់ព័ន្ធរបស់ពួកគេនៅក្នុងការចាប់ខ្លួនបន្ថែមទៀត។

សហព្រះរាជអាជ្ញាអន្តរជាតិនឹងស្នើសុំឲ្យបំពេញកិច្ចទាំងនេះ ដោយហេតុថាគាត់យល់ឃើញថាឧក្រិដ្ឋកម្មដែលត្រូវបានចោទនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ មិនត្រូវបានស៊ើបអង្កេតពេញលេញឡើយ។ សហព្រះរាជអាជ្ញាអន្តរជាតិមានកាតព្វកិច្ចតាមផ្លូវច្បាប់ក្រោមវិធានផ្ទៃក្នុងនិងក្រោមច្បាប់អ.វ.ត.ក ក្នុងការកំណត់និងស្នើឲ្យបំពេញកិច្ចស៊ើបសួរដែលសមហេតុផលដែលនឹងត្រូវអនុវត្តដោយសហចៅក្រមស៊ើបអង្កេតមុនពេលចេញសេចក្តីសម្រេចពាក់ព័ន្ធថាតើបុគ្គលណាគួរត្រូវបានចោទប្រកាន់និងបញ្ជូនទៅជំនុំជម្រះ។

## ការជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណីសក្តានុពលក្នុងសំណុំរឿង០០៣

អនុលោមតាមវិធាន២៣ស្ទួន បុគ្គលដែលមានបំណងចង់តាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០៣ ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរយ៉ាងយូរ១៥ថ្ងៃបន្ទាប់ពីសហចៅក្រមស៊ើបអង្កេតជូនដំណឹងដល់ភាគីទាំងអស់ អំពីការបញ្ចប់កិច្ចស៊ើបសួរតាមផ្លូវតុលាការ។ ដោយអនុវត្តបទបញ្ញត្តិច្បាប់ពាក់ព័ន្ធ សហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថាកាលបរិច្ឆេទចុងក្រោយសម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីគឺថ្ងៃពុធ ទី១៨ ខែឧសភា ឆ្នាំ២០១១ វេលាម៉ោង ៤រសៀល។

ដោយពិចារណាឃើញថាទីតាំងឧក្រិដ្ឋកម្មក្រោមការស៊ើបអង្កេតមិនត្រូវបានបង្ហាញជាសាធារណៈនាពេលកន្លងមកនោះ សហព្រះរាជអាជ្ញាអន្តរជាតិនឹងស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតពន្យារកាលបរិច្ឆេទចំនួនប្រាំមួយសប្តាហ៍ទៀតដើម្បីអនុញ្ញាតឲ្យជនរងគ្រោះមានពេលវេលាសមស្របក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ប៉ុន្តែនៅពេលបច្ចុប្បន្ននេះ ការធានាតែមួយគត់ដែលថាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវបានពិចារណាដោយសហចៅក្រមស៊ើបអង្កេតនោះ គឺត្រូវដាក់ពាក្យសុំឲ្យបានត្រឹមថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១១ វេលាម៉ោង៤រសៀល។ ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតពន្យារកាលបរិច្ឆេទចុងក្រោយ សាធារណជន នឹងទទួលបានការជូនដំណឹង។

យោងតាមវិធាន២៣ស្ទួន(១) និងមាត្រា៣.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ ជនរងគ្រោះត្រូវបានកំណត់និយមន័យថា គឺជារូបវន្តបុគ្គលឬនីតិបុគ្គលដែលទទួលរងព្យសនកម្មរាយកាយ សម្ភារៈ ឬចិត្តសាស្ត្រជាផលវិបាកដោយផ្ទាល់នៃឧក្រិដ្ឋកម្មយ៉ាងតិចចំនួនមួយ។

ជនរងគ្រោះដែលមានបំណងដាក់ពាក្យអាចទាក់ទងផ្នែកគាំពារជនរងគ្រោះបំពេញទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះនៅសប្តាហ៍នេះ។ ការិយាល័យបើកធ្វើការពីថ្ងៃចន្ទដល់ថ្ងៃសុក្រ លើកលែងតែថ្ងៃឈប់សម្រាក។ អាសយដ្ឋានមានដូចខាងក្រោម៖

**<u>ផ្នែកគាំពារជនរងគ្រោះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា</u>**

**ផ្លូវជាតិលេខ៤**

**សង្កាត់ចោមចៅ ខណ្ឌដង្កោ**

**ប្រអប់សំបុត្រ៧១**

**ភ្នំពេញ កម្ពុជា**

**ការិយាល័យនៅរាជធានី**

**ផ្ទះលេខ៦A**

**ផ្លូវលេខ២១ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន**

**ភ្នំពេញ កម្ពុជា**

**លេខទូរសព្ទ៖ ០២៣ ២១៤ ២៩១ ឬ០៩៧ ៧៤២ ៤២១៨**

## ការជូនដំណឹងដល់ដើមបណ្តឹងសក្តានុពលក្នុងសំណុំរឿង០០៣

បុគ្គលដែលមានព័ត៌មានពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលស្ថិតក្រោមការស៊ើបអង្កេតអាចដាក់ព័ត៌មាននោះមកសហព្រះរាជអាជ្ញាបាន។ តាមវិធាន៤៩(២) ពាក្យបណ្តឹងឬព័ត៌មានទាំងនេះ អាចត្រូវបានប្តឹងទៅសហព្រះរាជអាជ្ញាដោយបុគ្គលណាម្នាក់ អង្គការ ឬតាមប្រភពផ្សេងទៀត ជាជនដែលបានដឹងឮ ឬជាជនរងគ្រោះនៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ឬជាជនដែលបានដឹងអំពីបទឧក្រិដ្ឋដែលត្រូវចោទប្រកាន់នោះ។

វិធាន៤៩នៃវិធានផ្ទៃក្នុង ដាក់កាតព្វកិច្ចឲ្យសហព្រះរាជអាជ្ញាធ្វើការវាយតម្លៃលើពាក្យបណ្តឹង ឬព័ត៌មានដែលចោទថាមានការប្រព្រឹត្តបទល្មើសក្រោមយុត្តាធិការរបស់ អ.វ.ត.ក។ នៅពេលដែលសហព្រះរាជ

អាជ្ញា ទទួលពាក្យបណ្ដឹងឬព័ត៌មានពាក់ព័ន្ធនឹងការស៊ើបអង្កេតដែលកំពុងដំណើរការ សហព្រះរាជអាជ្ញាអាចបញ្ជូនពាក្យបណ្ដឹងឬព័ត៌មាននេះទៅសហចៅក្រមស៊ើបអង្កេតបញ្ចូលក្នុងសំណុំរឿងជាភស្តុតាង។ ពាក្យបណ្ដឹងឬព័ត៌មានអាចដាក់តាមរយៈផ្នែកគាំពារជនរងគ្រោះ ឬការិយាល័យព្រះរាជអាជ្ញាផ្ទាល់តែម្តង។ ទោះបីជាគ្មានកាលកំណត់ជាក់លាក់សម្រាប់ការដាក់ពាក្យបណ្ដឹងក៏ដោយ ក៏សហព្រះរាជអាជ្ញាលើកទឹកចិត្តឲ្យសាក្សីដែលមានបំណងដាក់ពាក្យបណ្ដឹងអំពីឧក្រិដ្ឋកម្មដូចបានរៀបរាប់នៅក្នុងសំណុំរឿង០០៣ ដាក់ពាក្យបណ្ដឹងឲ្យបានឆាប់តាមតែអាចធ្វើទៅបាន។